# " ខ្មែរអំបូរអ្នកកសាងគឺចេះការពារហើយ! "

១-ពូជខ្មែរជាអំបូរអ្នកកសាង មានជាតឹកតាងបង្ហាញយ៉ាងច្បាស់
មានប្រាង្គប្រាសាទខ្ពស់កប់អាកាស ដូចឋានកៃលាស់ឈរយ៉ាងស្កឹមស្កៃ
២-ប្រាសាទអង្គរប្រាសាទព្រះវិហារ អន្តរជាតិនាំគ្នាកោតស្ញប់ស្ញែង
ស្នាដៃដូនតាល្អឆើតក្រៃលែង នេះសអោយស្តែងមោទនៈជាតិខ្មែរ ។
៣-ព្រះវិហារជាបេតិកភណ្ឌពិភពលោក កូនខ្មែរគ្រប់រូបសែនរីករាយក្រៃ
វាយជួងទូងស្គរអបអរថ្ងៃជ័យ ទាំងប្រុសទាំងស្រីញញឹមសប្បាយ ។
៤-ឃើញជនរួមឈាមញញឹមសប្បាយ ទ័ពខ្មែរទាំងឡាយនៅសមរភូមិមុខ
មានចិត្តតស៊ូប្តេជ្ញាមោះមុត ដៃកាន់អាវុធត្រៀមការពារជាតិ ។
៥-ពេលខ្មែរប្រារព្ធខួបថ្ងៃជោគជ័យ បែរសៀមអប្រិយមានចិត្តច្រណែន
បន្ថែមទ័ពខ្លួនវាយតាមជាយដែន រួចស្រែកក្តែងៗថាមិនសុខចិត្ត ។
៦-សៀមមិនលះបង់ចិត្តមហិច្ឆតា ព្រុសស្រែកតវ៉ាជាមួយ UNESCO
សុំអោយអង្គការវប្បធម៌ប្តូរ ដើម្បីជាថ្នូរខ្លួនបានចូលដែរ ។
៧-ពេល UNESCO បដិសេធ សៀមមិនទាន់ឆ្អែតចិញ្ចឹមចិត្តតវ៉ា
អួតប្រាប់ជាតិសាសន៍ខ្លួនយ៉ាងខ្លាំងក្លា ស្រែកថាអង្គការពិចារណាឆ្នាំក្រោយ ។
៨-រឿងមួយទៀតកូនខ្មែរសែនហួសចិត្ត សៀមថាខ្មែរពិតមិនអាចការពារ
ម្នាក់ឯងបានទេទាល់តែរួមគ្នា ជាមួយពួកវាទើបអាចគង់វង់ ។
៩-មិនបាច់ព្រុសដូច្នេះទេសៀមអើយ កូនខ្មែរចេះហើយរឿងអភិរក្ស
ពូជអ្នកកសាងតែងតែជឿជាក់ ចេះថ្នមចេះថ្នាក់ចេះការពារហើយ ។

គោរពជូនដោយ-អាណាចក្រខ្មែរ
Email: anachakkhmer@yahoo.com